# លិខិតរបស់គ្រីស្តទូតប៉ូល
# ផ្ញើជូនគ្រីស្តបរិស័ទក្រុងកូឡូស

## ពាក្យលំនាំ

**ក្រុងកូឡូស** ៖ ក្រុងនេះស្ថិតនៅស្រុកព្រីគី គឺប្រមាណ ២០០ គ.ម ខាងកើតក្រុងអេភេសូ (សព្វថ្ងៃនៅកណ្តាលប្រទេសទួរគី)។

**ព្រះសហគមន៍ក្រុងកូឡូស** ៖ គ្រីស្តទូតប៉ូល មិនដែលមកក្រុងកូឡូសនោះទេ (១,៤;២,១)។ ពេលលោកស្ថិតនៅក្រុងអេភេសូ អស់រយៈពេលជាងពីរឆ្នាំកន្លះ (កក ១៩,១០) លោកអេប៉ាប្រាស ជាអ្នកក្រុងកូឡូស និងជាសាវ័ករបស់លោក (៤,១២ ) នាំដំណឹងល្អទៅក្រុងនោះ ព្រមទាំងតែងតាំងព្រះសហគមន៍ នៅក្រុងយេរាប៉ូលី និងក្រុងឡៅឌីសេ ( ៤,១៣; វរ ៣, ១៤-២២)។ គ្រីស្តបរិស័ទកូឡូស ចូលចិត្តរិះគិតតាមទស្សនវិជ្ជាក្រិក ស្ដីអំពីធាតុទាំងបួន (ទឹក ភ្លើង ខ្យល់ ដី) និងអំពីអំណាចទាំងឡាយដែលត្រួតត្រាពិភពលោក មានយមយក្ស អារក្ស អ្នកតា ទេវតាព្រៃភ្នំ វត្ថុស័ក្ដិសិទ្ធិជាដើម។ គ្រីស្តបរិស័ទខ្លះរាប់បញ្ចូលព្រះគ្រីស្ត ក្នុងចំណោមអំណាចទាំងនោះដែរ។

### លិខិតគ្រីស្តទូតប៉ូល

លោកអេប៉ាប្រាសជម្រាបដំណឹងនេះមកគ្រីស្តទូតប៉ូល នៅពេលលោកជាប់ឃុំឃាំង (៤,៧)។ គ្រីស្តទូតប៉ូលសរសេរលិខិតដើម្បីបញ្ជាក់ថា ព្រះយេស៊ូពិតជាមនុស្ស ដូចមនុស្សឯទៀតៗ ហើយព្រះអង្គក៏ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែរ។ ព្រះអង្គជាព្រះអម្ចាស់ដែលគ្រប់គ្រងលើសត្វទាំងអស់ ទ្រង់ក៏មានអំណាចលើវត្ថុស័ក្ដិសិទ្ធិទាំងឡាយ ទាំងនៅលើផែនដី ទាំងនៅលើមេឃ។ ព្រះអង្គសម្រុះសម្រួលមនុស្សលោក ឲ្យរស់នៅជាមួយគ្នាដោយសេចក្ដីសុខសាន្ត។ ព្រះសហគមន៍ពិតជាព្រះកាយរបស់ព្រះគ្រីស្ត ហើយព្រះអង្គក៏ជាសិរសារបស់ព្រះសហគមន៍នេះដែរ។

គ្រីស្តទូតប៉ូលផ្ញើជូនលិខិតនេះ ដោយសារលោកទីឃីគូសនិងលោកអូនេស៊ីម (៤,៧-៩)។

# លិខិតរបស់គ្រីស្ដទូតប៉ូល ផ្ញើជូនគ្រីស្ដបរិស័ទក្រុងកូឡូស

## សូមជម្រាបសួរ

១ខ្ញុំ ប៉ូលដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ
១តែងតាំងជាគ្រីស្ដទូតរបស់ព្រះគ្រីស្ដយេស៊ូ
និងបងធីម៉ូថេ ២សូមជម្រាបមកជនដ៏វិសុទ្ធ*
ជាបងប្អូនរួមជំនឿក្នុងអង្គព្រះគ្រីស្ដ ដែលនៅ
ក្រុងកូឡូស។ សូមព្រះជាម្ចាស់ជាព្រះបិតា
របស់យើងប្រោសប្រណី និងប្រទានសេចក្ដី
សុខសាន្ដដល់បងប្អូន។

## ពាក្យអរព្រះគុណ

៣យើងសូមអរព្រះគុណព្រះជាម្ចាស់ ជាព្រះ
បិតារបស់ព្រះយេស៊ូគ្រីស្ដ* ជាអម្ចាស់នៃយើង
ជានិច្ច គ្រប់ពេលដែលយើងអធិស្ឋាន*ឲ្យបង
ប្អូន ៤ដ្បិតយើងបានឮគេនិយាយអំពីជំនឿរបស់
បងប្អូនលើព្រះគ្រីស្ដយេស៊ូ និងអំពីសេចក្ដី
ស្រឡាញ់របស់បងប្អូន ចំពោះជនដ៏វិសុទ្ធ*ទាំង
អស់ ៥ព្រោះតែសេចក្ដីសង្ឃឹមដែលព្រះអង្គ
បម្រុងទុកសម្រាប់បងប្អូន នៅស្ថានបរមសុខ។
បងប្អូនបានស្ដាប់អំពីសេចក្ដីសង្ឃឹមនេះ ដោយ
សារព្រះបន្ទូលនៃសេចក្ដីពិត គឺដំណឹងល្អ*
៦ដែលបានមកដល់បងប្អូន។ ចាប់តាំងពីថ្ងៃ
ដែលបងប្អូនបានទទួល និងបានស្គាល់ព្រះ
ហឫទ័យប្រោសប្រណី របស់ព្រះជាម្ចាស់ ស្រប
តាមសេចក្ដីពិតនោះមក ដំណឹងល្អនេះបាន
បង្កើតផល និងចម្រើនឡើង ក្នុងចំណោមបង
ប្អូន ដូចនៅក្នុងពិភពលោកទាំងមូលដែរ។៧បង
ប្អូនបានទទួលការអប់រំនេះ ពីសំណាក់បងអេប៉ា
ប្រាសដ៏ជាទីស្រឡាញ់ ដែលរួមការងារជាមួយ
យើង។ គាត់ជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះ
គ្រីស្ដ សម្រាប់បងប្អូន។ ៨គាត់បានប្រាប់ឲ្យ
យើងដឹងច្បាស់ អំពីសេចក្ដីស្រឡាញ់ដែលព្រះ
វិញ្ញាណប្រទានមកបងប្អូន។

៩ហេតុនេះ ចំពោះយើងតាំងពីយើងឮ
ដំណឹងពីបងប្អូន យើងចេះតែអធិស្ឋាន និងទូល
អង្វរព្រះជាម្ចាស់ឲ្យបងប្អូន ឥតឈប់ឈរឡើយ
ដើម្បីឲ្យបងប្អូនស្គាល់ព្រះហឫទ័យ របស់ព្រះ
អង្គយ៉ាងច្បាស់ ដោយមានគ្រប់ប្រាជ្ញា និង
តម្រិះដែលមកពីព្រះវិញ្ញាណ។ ១០សូមឲ្យបង
ប្អូនរស់នៅបានសមរម្យនឹងព្រះអម្ចាស់ ដើម្បីឲ្យ
បានគាប់ព្រះហឫទ័យព្រះអង្គ ក្នុងគ្រប់វិស័យ
ទាំងអស់។ ដូច្នេះបងប្អូននឹងបង្កើតផលក្នុង
គ្រប់អំពើល្អដែលបងប្អូនធ្វើហើយបងប្អូននឹង
ស្គាល់ព្រះជាម្ចាស់ កាន់តែច្បាស់ឡើងៗ។
១១សូមឲ្យបងប្អូនមានកម្លាំងមាំមួន គ្រប់ជំពូក

ដោយព្រះចេស្ដាដ៏រុងរឿងរបស់ព្រះអង្គ ដើម្បី
ឲ្យបងប្អូនអាចស៊ូទ្រាំនឹងអ្វីៗទាំងអស់ និង ចេះ
អត់ធ្មត់ទៀតផង។

១២ចូរអរព្រះគុណព្រះបិតាដោយចិត្តរីករាយ
ព្រោះព្រះអង្គបានប្រោសប្រទាន ឲ្យបងប្អូន
មានសមត្ថភាព អាចទទួលចំណែកមត៌ករួម
ជាមួយជនដ៏វិសុទ្ធ* នៅក្នុងពន្លឺ។ ១៣ព្រះអង្គ
បានរំដោះយើង ឲ្យរួចផុតពីអំណាចនៃសេចក្ដី
ងងឹត ហើយចម្លងយើងចូលទៅក្នុងព្រះរាជ្យ*
នៃព្រះបុត្រា ដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។
១៤ ដោយយើងរួមក្នុងអង្គព្រះបុត្រា ព្រះអង្គបាន
លោះយើង និង លើកលែងទោសយើង ឲ្យរួចពី
បាប។

១៥ព្រះគ្រីស្ដ ជាតំណាង[ក]របស់ព្រះជាម្ចាស់
ដែលយើងមើលពុំឃើញ ព្រះអង្គជារៀមច្បងនៃ
អ្វីៗទាំងអស់ ដែលព្រះជាម្ចាស់បានប្រតិស្ឋាន
មក ១៦ដ្បិត ព្រះជាម្ចាស់បានប្រតិស្ឋានអ្វីៗសព្វ
សារពើក្នុងអង្គព្រះគ្រីស្ដ ទាំងនៅលើមេឃ*
ទាំងនៅលើផែនដី ទាំងអ្វីៗដែលមើលឃើញ
ទាំងអ្វីៗដែលមើលមិនឃើញ ទាំងពួកទេវតា[ខ]
ទាំងម្ចាស់ទឹកម្ចាស់ដី ទាំងវត្ថុសក្ដិសិទ្ធិ និងអ្វីៗ
ដែលមានអំណាច ព្រះជាម្ចាស់បានប្រតិស្ឋាន
ទាំងអស់មក ដោយសារព្រះគ្រីស្ដ និង សម្រាប់
ព្រះគ្រីស្ដ។

១៧ព្រះគ្រីស្ដមានព្រះជន្ម មុនអ្វីៗទាំងអស់
ហើយអ្វីៗទាំងអស់ក៏នៅស្ថិតស្ថេររួមគ្នា ដោយ
សារព្រះអង្គដែរ។ ១៨ព្រះអង្គជាសិរសានៃព្រះ
កាយរបស់ព្រះអង្គ គឺព្រះសហគមន៍។ ព្រះអង្គ
ជាដើមកំណើតនៃអ្វីៗទាំងអស់។ ក្នុងចំណោម
មនុស្សស្លាប់ទាំងអស់ ព្រះអង្គមានព្រះជន្មថ្មីដ៏
រុងរឿងមុនគេ[គ] ដើម្បីធ្វើជាប្រមុខក្នុងគ្រប់វិស័យ
ទាំងអស់ ១៩ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យ
ឲ្យគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ ស្ថិតនៅ
ក្នុងព្រះគ្រីស្ដ។ ២០ព្រះជាម្ចាស់បានសម្រុះ
សម្រួលអ្វីៗទាំងអស់នៅលើផែនដី និង នៅលើ
មេឃឲ្យជានានឹងព្រះអង្គវិញ ដោយសារព្រះគ្រី
ស្ដ និង សម្រាប់ព្រះគ្រីស្ដ គឺព្រះជាម្ចាស់បានធ្វើ
ឲ្យមានសន្តិភាព ដោយព្រះបុត្រាបង្ហូរព្រះ
លោហិត នៅលើឈើឆ្កាង។

២១ចំពោះបងប្អូនវិញ ពីដើមបងប្អូនជាជន
បរទេសឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ហើយជា
សត្រូវនឹងព្រះអង្គ ព្រោះតែគំនិតនិងអំពើ
អាក្រក់របស់បងប្អូន។ ២២តែឥឡូវនេះព្រះអង្គ
បានសម្រុះសម្រួលបងប្អូនឲ្យជានា នឹងព្រះអង្គ
វិញ ដោយព្រះបុត្រាដែលកើតមកជាមនុស្ស
បានសោយទិវង្គត ដើម្បីឲ្យបងប្អូនបានវិសុទ្ធ*
ឥតសៅហ្មង ឥតកំហុស និងអាចឈរនៅ
ចំពោះព្រះភក្ត្ររបស់ព្រះអង្គ។ ២៣ក៏ប៉ុន្តែបង
ប្អូនត្រូវតែកាន់ជំនឿឲ្យបានរឹងប៉ឹងខ្ជាប់ខ្ជួន
ដើម្បីកុំឲ្យឃ្លាតចាកពីសេចក្ដីសង្ឃឹម ដែលបង
ប្អូនមានតាំងពីបានឮដំណឹងល្អ*មកនោះ គឺជា
ដំណឹងល្អដែលគេបានប្រកាស ដល់មនុស្ស

លោកទាំងអស់នៅក្រោមមេឃ ហើយខ្ញុំប៉ូល
បានទទួលមុខងារបម្រើដំណឹងល្អនេះដែរ។

## កិច្ចការដ៏លំបាករបស់គ្រីស្តទូត

២៤ឥឡូវនេះ ខ្ញុំមានអំណរដោយរងទុក្ខ
លំបាកសម្រាប់បងប្អូន ព្រោះខ្ញុំរងទុក្ខលំបាក
ក្នុងរូបកាយដូច្នេះ ដើម្បីជួយបំពេញទុក្ខលំបាក
របស់ព្រះគ្រីស្ត សម្រាប់ព្រះកាយរបស់ព្រះអង្គ
ដែលជាព្រះសហគមន៍*។ ២៥ខ្ញុំបានទទួលមុខ
ងារបម្រើព្រះសហគមន៍នេះ តាមការចាត់ចែង
ដែលព្រះជាម្ចាស់បានផ្ទុកផ្ដាក់ឲ្យខ្ញុំធ្វើ គឺណែនាំ
បងប្អូនឲ្យស្គាល់ព្រះបន្ទូលរបស់ព្រះអង្គបាន
សព្វគ្រប់។ ២៦នេះហើយជាគម្រោងការដ៏លាក់
កំបាំង ដែលព្រះជាម្ចាស់បានលាក់ទុកតាំងពី
យូរអង្វែងតរៀងមក មិនឲ្យមនុស្សជំនាន់មុនៗ
ស្គាល់ឡើយ តែឥឡូវនេះ ព្រះអង្គបានបង្ហាញ
ឲ្យជនដ៏វិសុទ្ធ* របស់ព្រះអង្គស្គាល់។២៧ព្រះជា
ម្ចាស់សព្វព្រះហឫទ័យ ឲ្យជនដ៏វិសុទ្ធនេះ
ស្គាល់សិរីរុងរឿងដ៏ប្រសើរបំផុត នៃគម្រោងការ
នេះ នៅក្នុងចំណោមសាសន៍ដទៃ ពោលគឺព្រះ
គ្រីស្តគង់នៅក្នុងបងប្អូនព្រះអង្គប្រទាន ឲ្យបង
ប្អូនមានសង្ឃឹមថា នឹងបានទទួលសិរីរុងរឿង
របស់ព្រះអង្គ។ ២៨ដូច្នេះយើងនាំដំណឹងអំពីព្រះ
គ្រីស្តនេះ ហើយយើងក៏ដាស់តឿន និង ប្រៀន
ប្រដៅមនុស្សគ្រប់ៗរូប ដោយប្រើប្រាជ្ញាគ្រប់
យ៉ាង ធ្វើឲ្យគេទាំងអស់គ្នាបានគ្រប់លក្ខណៈ
ក្នុងអង្គព្រះគ្រីស្ត។ ២៩ខ្ញុំធ្វើការនឿយហត់ដើម្បី
សម្រេចគោលដៅនេះឯង គឺខំប្រឹងតយុទ្ធ
ដោយប្រើមហិទ្ធិឫទ្ធិរបស់ព្រះអង្គ ដែលកំពុងតែ
មានសកម្មភាពក្នុងរូបខ្ញុំយ៉ាងខ្លាំង។

១ខ្ញុំចង់ឲ្យបងប្អូនជ្រាបថា ខ្ញុំតយុទ្ធខ្លាំងក្លា
២យ៉ាងណាសម្រាប់បងប្អូន សម្រាប់អស់អ្នក
នៅស្រុកឡៅឌីសេ និងអស់អ្នកដែលមិនធ្លាប់
បានឃើញមុខខ្ញុំផ្ទាល់ ២គឺខ្ញុំចង់លើកទឹកចិត្ត
បងប្អូនទាំងនោះ ឲ្យរួបរួមគ្នាក្នុងសេចក្ដី
ស្រឡាញ់ ដើម្បីឲ្យគេមានប្រាជ្ញាវាងវៃបំផុត
យល់សព្វគ្រប់ទាំងអស់ និងស្គាល់ច្បាស់នូវ
គម្រោងការដ៏លាក់កំបាំង របស់ព្រះជាម្ចាស់
ពោលគឺព្រះគ្រីស្តផ្ទាល់ ៣ដ្បិតព្រះតម្រិះ និង
ព្រះប្រាជ្ញាញាណដ៏ខ្ពង់ខ្ពស់[ឃ]របស់ព្រះជាម្ចាស់
សុទ្ធតែលាក់ទុកក្នុងអង្គព្រះគ្រីស្តហ្នឹងហើយ។
៤ខ្ញុំនិយាយដូច្នេះ ដើម្បីការពារកុំឲ្យនរណា
ម្នាក់អាចមកបញ្ឆោតបងប្អូន ដោយពាក្យសំដីដ៏
ពីរោះៗនោះឡើយ។ ៥ថ្វីដ្បិតតែខ្លួនខ្ញុំនៅឆ្ងាយ
ពីបងប្អូន តែចិត្តខ្ញុំ[ង]នៅជាប់ជាមួយបងប្អូន
ហើយខ្ញុំក៏មានអំណរ ដោយឃើញបងប្អូនមាន
សណ្ដាប់ធ្នាប់ និងមានជំនឿមាំមួន ទៅលើព្រះ
គ្រីស្ត។

## ជីវិតរួមជាមួយព្រះគ្រីស្ត

៦ដូច្នេះ បើបងប្អូនបានទទួលព្រះគ្រីស្ត
យេស៊ូ ទុកជាព្រះអម្ចាស់យ៉ាងណាហើយ ចូរ

រស់នៅរួមជាមួយព្រះអង្គយ៉ាងនោះ តទៅទៀត
ទៅ។ ៧ចូរចាក់ឫសនិងកសាងជីវិតលើព្រះអង្គ
ចូររក្សាជំនឿឲ្យបានរឹងប៉ឹង ស្របតាមសេចក្ដី
ប្រៀនប្រដៅដែលបងប្អូនបានទទួល ហើយត្រូវ
អរព្រះគុណព្រះជាម្ចាស់ ឲ្យបានច្រើនលើសល
ប់។

៨ចូរប្រយ័ត្ន កុំឲ្យនរណាម្នាក់មកទាក់ទាញ
បងប្អូនបាន ដោយប្រើទស្សនវិជ្ជា ឬប្រើពាក្យ
បោកបញ្ឆោតឥតខ្លឹមសារ ស្របតាមសេចក្ដី
ប្រៀនប្រដៅរបស់មនុស្សតៗគ្នាមក និងស្រប
តាមអ្វីៗជាធាតុអរូបី ដែលមានឥទ្ធិពលលើ
លោកីយ៍[ច] គឺមិនស្របតាមព្រះគ្រីស្ដទេ ៩ដ្បិត
គ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ស្ថិតនៅ
យ៉ាងពោរពេញក្នុងរូបកាយព្រះគ្រីស្ដ។ ១០រីឯ
បងប្អូនក៏បានពោរពេញដូច្នោះដែរ ព្រះអង្គ
ដែលជាម្ចាស់លើវត្ថុសក្ដិសិទ្ធិ និងលើអ្វីៗទាំង
អស់ដែលមានអំណាច។

១១ក្នុងអង្គព្រះគ្រីស្ដ បងប្អូនក៏បានទទួល
ពិធីកាត់ស្បែក*ម្យ៉ាង មិនមែនធ្វើដោយដៃ
មនុស្សទេ គឺបងប្អូនបានដោះរូបកាយខាង
លោកីយ៍ចេញ នេះហើយជាពិធីកាត់ស្បែកតាម
របៀបព្រះគ្រីស្ដ។ ១២ដោយបងប្អូនទទួលពិធី
ជ្រមុជទឹក* បងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះ
គ្រីស្ដ ហើយដោយបងប្អូនរួមក្នុងអង្គព្រះគ្រីស្ដ
បងប្អូនក៏ទទួលជីវិតថ្មី រួមជាមួយព្រះអង្គដែរ
ព្រោះបងប្អូនមានជំនឿ លើឫទ្ធានុភាពរបស់
ព្រះជាម្ចាស់ ដែលបានប្រោសព្រះគ្រីស្ដឲ្យមាន
ព្រះជន្មថ្មីដ៏រុងរឿង។ ១៣ពីដើមបងប្អូនបាន
ស្លាប់មកពីកំហុសរបស់បងប្អូន និងមកពីបង
ប្អូនពុំបានទទួលពិធីកាត់ស្បែក ខាងរូបកាយ[ឆ]
មែន តែឥឡូវនេះ ព្រះជាម្ចាស់បានប្រោសឲ្យ
បងប្អូនមានជីវិតរួមជាមួយព្រះគ្រីស្ដ។ ព្រះអង្គ
បានលើកលែងទោសទាំងប៉ុន្មាន របស់យើង។
១៤ព្រះអង្គបានលុបបញ្ជីដែលចោទប្រកាន់ទាស់
នឹងយើង[ជ]តាមធម្មវិន័យនោះចោល។ ព្រះអង្គ
បានដកបញ្ជីនេះចេញ ដោយយកទៅបោះភ្ជាប់
នឹងឈើឆ្កាង។ ១៥ព្រះអង្គបានដកឫទ្ធិចេញពីវត្ថុ
សក្ដិសិទ្ធិ និងពីអ្វីៗដែលមានអំណាច គឺព្រះអង្គ
បានបំបាក់មុខពួកវា ជាសាធារណៈទាំងនាំវា
ទៅជាឈ្លើយ ក្នុងពេលហែក្បួនជ័យជម្នះរបស់
ព្រះអង្គ[ឈ]។

១៦ហេតុនេះ មិនត្រូវឲ្យនរណាម្នាក់ថ្កោល
ទោសបងប្អូនអំពីរឿងចំណីអាហារ ភេសជ្ជៈ ឬ
អំពីរឿងបុណ្យទាន បុណ្យចូលខែ និងថ្ងៃសប្ប័
ទ*នោះឡើយ។ ១៧ការទាំងអស់នេះគ្រាន់តែ
ជាស្រមោលនៃអ្វីៗ ដែលនឹងកើតមាននៅ
អនាគតកាលប៉ុណ្ណោះ រីឯអ្វីៗដែលពិតវិញ គឺ
ព្រះគ្រីស្ដ។ ១៨មិនត្រូវឲ្យនរណាម្នាក់មកបង្វែរ
បងប្អូនចេញពីរង្វាន់ ដែលបងប្អូនត្រូវទទួល
ដោយធ្វើឫកជាដាក់ខ្លួន ឬគោរពទេវទូត*នោះ
ឡើយ។ ជនបែបនេះតែងយកការនិមិត្តឃើញ
របស់ខ្លួនមកធ្វើជាទីសំអាងហើយគេអួតបំប៉ោង

ឥតបានការ តាមគំនិតលោកីយ៍។ ១៩គេមិននៅ
ជាប់ជាមួយព្រះគ្រីស្ទ ជាព្រះសិរសាទេ គឺព្រះ
សិរសានេះហើយ ដែលផ្គត់ផ្គង់ឲ្យព្រះកាយ
ទាំងមូលតភ្ជាប់គ្នា ដោយសន្លាក់ឆ្អឹងនិងសរសៃ
ព្រមទាំងចម្រើនឡើង តាមតែព្រះជាម្ចាស់
ប្រទានឲ្យ។

## ស្លាប់ និង រស់ រួមជាមួយព្រះគ្រីស្ទ

២០ដោយបងប្អូនស្លាប់ រួមជាមួយព្រះគ្រីស្ទ
ហើយ បងប្អូនក៏រួចផុតពីធាតុដ៏អរូបី ដែលមាន
ឥទ្ធិពលក្នុងលោកីយ៍នោះដែរ ចុះហេតុដូចម្ដេច
បានជាបងប្អូន នៅតែធ្វើតាមក្បួនតម្រាផ្សេងៗ
ហាក់បីដូចជាបងប្អូននៅតែពឹងផ្អែកលើ
លោកីយ៍នេះទៀត? ២១«កុំយក! កុំភ្លក់! កុំប៉ះ
ពាល់!» ២២បញ្ញត្តិទាំងនេះសុទ្ធតែជាបទបញ្ជា
និងសេចក្ដីប្រៀនប្រដៅរបស់មនុស្សលោកជាប់
ទាក់ទងនឹងអ្វីៗ ដែលត្រូវរលួយដោយការប្រើ
ប្រាស់។ ២៣សេចក្ដីក្នុងបញ្ញត្តិទាំងនេះទំនងដូច
ជាមានប្រាជ្ញា គឺឲ្យគោរពថ្វាយបង្គំដោយស្ម័គ្រ
ចិត្តឲ្យដាក់ខ្លួន និងលត់ដំខ្លួនជាដើម តែតាម
ពិតគ្មានតម្លៃអ្វីសោះ បានត្រឹមតែបំពេញសេចក្ដី
ប៉ងប្រាថ្នា របស់លោកីយ៍ប៉ុណ្ណោះ។

៣ ១ដោយបើបងប្អូនទទួលជីវិតថ្មីរួមជាមួយ
ព្រះគ្រីស្ទដូច្នេះហើយ ចូរស្វែងរកអ្វីៗនៅស្ថាន
លើ ជាស្ថានដែលព្រះគ្រីស្ទគង់នៅខាងស្ដាំព្រះ
ជាម្ចាស់នោះវិញ។ ២ចូរគិតពីអ្វីៗដែលនៅស្ថាន
លើ កុំគិតពីអ្វីនៅលើផែនដីនេះឡើយ ៣ដ្បិត
បងប្អូនបានស្លាប់ផុតទៅហើយ ហើយជីវិត
របស់បងប្អូនក៏កប់ទុកជាមួយព្រះគ្រីស្ទ ក្នុងព្រះ
ជាម្ចាស់ដែរ។ ៤ពេលព្រះគ្រីស្ទដែលជាជីវិត
របស់បងប្អូនលេចមក បងប្អូនក៏នឹងលេចមក
ជាមួយព្រះគ្រីស្ទ ប្រកបដោយសិរីរុងរឿងដែរ។

## ជីវិតចាស់ និង ជីវិតថ្មី

៥ដូច្នេះ សូមបងប្អូនសម្លាប់អ្វីៗខាង
លោកីយ៍ចោលទៅ គឺអំពើប្រាសចាកសីលធម៌
អំពើសៅហ្មង ចិត្តស្រើបស្រាលបំណងប្រាថ្នា
អាក្រក់ និងចិត្តលោភលន់គឺយកទ្រព្យសម្បត្តិ
ធ្វើជាព្រះ។ ៦ព្រោះតែអំពើទាំងនោះហើយ
បានជាព្រះជាម្ចាស់ ទ្រង់ព្រះពិរោធនឹងពួកអ្នក
ប្រឆាំងព្រះអង្គ។ ៧កាលពីដើមបងប្អូនប្រព្រឹត្ត
អំពើទាំងនោះ ហើយក៏រស់នៅបែបដូច្នោះដែរ។
៨តែឥឡូវនេះ សូមបងប្អូនបោះបង់កំហឹងចិត្ត
ក្ដៅក្រហាយ ចិត្តអាក្រក់ ពាក្យជេរប្រមាថ
ពាក្យទ្រគោះបោះបោក ដែលចេញពីមាត់របស់
បងប្អូនចោលទៅ។ ៩កុំនិយាយកុហកគ្នាទៅ
វិញទៅមកឡើយ ដ្បិតបងប្អូនបានដោះជីវិត
ចាស់ និងទម្លាប់អាក្រក់ទាំងប៉ុន្មានរបស់ជីវិត
នោះចោលហើយ ១០បងប្អូនក៏បានពាក់ជីវិតថ្មី
ដែលកាន់តែចម្រើនថ្មីឡើងៗ ឲ្យបានដូចព្រះ
ជាម្ចាស់ ដែលបង្កើតមនុស្សថ្មីនោះ ដើម្បីឲ្យបង
ប្អូនស្គាល់ព្រះអង្គយ៉ាងច្បាស់។ ១១ដូច្នេះលែង

មានសាសន៍ក្រិក ឬសាសន៍យូដាពួកកាត់
ស្បែក*ឬមិនកាត់ស្បែក មនុស្សព្រៃឬព្នង[ញ]
និងក៏លែងមានទាសករ ឬអ្នកជាទៀតឡើយ
ដ្បិតព្រះគ្រីស្តបានបំពេញអ្វីៗទាំងអស់ ហើយ
ព្រះអង្គសណ្ឋិតនៅក្នុងមនុស្សទាំងអស់។

[១២]ដោយព្រះជាម្ចាស់ បានជ្រើសរើសបង
ប្អូនធ្វើជាជនដ៏វិសុទ្ធ* និងជាទីស្រឡាញ់របស់
ព្រះអង្គ បងប្អូនត្រូវតែកាន់ចិត្តអាណិតមេត្តា
ចិត្តល្អ សប្បុរស ចេះបន្ទាបខ្លួន មានចិត្តស្លូត
បូត និងចិត្តខន្តីអត់ធ្មត់។ [១៣]ត្រូវចេះទ្រាំទ្រគ្នា
ទៅវិញទៅមក ហើយប្រសិនបើបងប្អូនណា
ម្នាក់មានរឿងអ្វីមួយនឹងម្នាក់ទៀត ត្រូវតែអត់
ទោសឲ្យគ្នាទៅវិញទៅមក។ ព្រះអម្ចាស់បាន
អត់ទោសឲ្យបងប្អូនយ៉ាងណា ចូរអត់ទោសឲ្យ
គ្នាទៅវិញទៅមកយ៉ាងនោះដែរ។ [១៤]លើសពី
នេះទៅទៀត ត្រូវមានចិត្តស្រឡាញ់ ដ្បិត
សេចក្តីស្រឡាញ់ ធ្វើឲ្យបងប្អូនរួបរួមគ្នាពេញ
លក្ខណៈ[ដ]។ [១៥]សូមឲ្យសេចក្តីសុខសាន្តរបស់
ព្រះគ្រីស្តសោយរាជ្យ[ឋ] នៅក្នុងចិត្តបងប្អូន
ព្រោះព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យ
មករួមគ្នាក្នុងព្រះកាយតែមួយ ដើម្បីឲ្យបងប្អូន
ប្រកបដោយសេចក្តីសុខសាន្ត។ ត្រូវអរព្រះ
គុណព្រះអង្គជានិច្ច។

[១៦]សូមព្រះបន្ទូលរបស់ព្រះគ្រីស្ត សណ្ឋិត
នៅក្នុងបងប្អូនឲ្យបានបរិបូណ៌។ ចូរប្រៀន
ប្រដៅនិងដាស់តឿនគ្នាទៅវិញទៅមក ដោយ
ប្រាជ្ញាគ្រប់យ៉ាង។ ចូរច្រៀងអរព្រះគុណព្រះជា
ម្ចាស់ក្នុងចិត្ត ដោយប្រើទំនុកតម្កើងបទសរសើរ
និងបទចម្រៀងមកពីព្រះវិញ្ញាណ។ [១៧]ការអ្វីក៏
ដោយដែលបងប្អូនធ្វើ ទោះជាពាក្យសំដីឬកាយ
វិការក្តី ត្រូវធ្វើក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ
ទាំងអស់ ទាំងអរព្រះគុណព្រះជាម្ចាស់ជាព្រះ
បិតា ដោយព្រះអង្គផង។

## ក្រុមគ្រួសាររបស់គ្រីស្តបរិស័ទ

[១៨]បងប្អូនជាស្រ្តីដែលមានស្វាមី ចូរគោរព
ស្វាមីរៀងៗខ្លួន ឲ្យបានស្របតាមរបៀបអ្នកជឿ
លើព្រះអម្ចាស់។

[១៩]បងប្អូនដែលមានភរិយា ចូរស្រឡាញ់
ភរិយារបស់ខ្លួន កុំមួម៉ៅដាក់នាងឡើយ។

[២០]កុមារាកុមារី ចូរស្តាប់បង្គាប់មាតាបិតា
ក្នុងគ្រប់កិច្ចការទាំងអស់ ធ្វើដូច្នេះទើបគាប់ព្រះ
ហឫទ័យព្រះអម្ចាស់។

[២១]បងប្អូនដែលមានកូន ចូរកុំដុកដាន់កូន
របស់ខ្លួនឡើយ ក្រែងលោវាបាក់ទឹកចិត្ត។

[២២]បងប្អូនជាទាសករ ចូរស្តាប់បង្គាប់ម្ចាស់
របស់ខ្លួនក្នុងលោកនេះ គ្រប់ជំពូកទាំងអស់។
ត្រូវធ្វើដូច្នេះ មិនគ្រាន់តែឲ្យម្ចាស់ទាំងនោះ
ឃើញ ដូចជាបងប្អូនចង់ផ្គាប់ចិត្តមនុស្សឡើយ
គឺត្រូវធ្វើដោយចិត្តស្មោះសរ និងដោយគោរព
កោតខ្លាចព្រះអម្ចាស់។ [២៣]គ្រប់កិច្ចការដែល

បងប្អូនធ្វើ ចូរធ្វើឲ្យអស់ពីចិត្ត ដូចជាធ្វើថ្វាយព្រះអម្ចាស់ដែរ គឺមិនមែនធ្វើសម្រាប់មនុស្សលោកទេ ២៤ដោយដឹងថា បងប្អូនមុខជាទទួលមត៌កពីព្រះអម្ចាស់ទុកជាកម្រៃមិនខាន។ ម្ចាស់ដ៏ពិតប្រាកដគឺព្រះគ្រីស្ត ចូរបម្រើព្រះអង្គទៅ។ ២៥អ្នកណាធ្វើការអ្វីដោយទុច្ចរិត អ្នកនោះក៏នឹងទទួលផលតាមអំពើទុច្ចរិតនោះដែរ ដ្បិតព្រះជាម្ចាស់មិនរើសមុខនរណាឡើយ។

១បងប្អូនដែលជាម្ចាស់ ចូរប្រព្រឹត្តអំពើណា៤ដែលសុចរិតនិងយុត្តិធម៌ដល់ទាសកររបស់ខ្លួន ដោយដឹងថា បងប្អូនផ្ទាល់ក៏មានម្ចាស់មួយព្រះអង្គនៅស្ថានបរមសុខ*ដែរ។

## ពាក្យដាស់តឿន

២ចូរព្យាយាមអធិស្ឋាន* នាំឲ្យខ្លួនប្រុងស្មារតីអរព្រះគុណព្រះជាម្ចាស់ផង។ ៣ចូរទូលអង្វរព្រះជាម្ចាស់ឲ្យយើងដែរ ដើម្បីព្រះអង្គបើកទ្វារចំហ ឲ្យយើងមានឱកាសប្រកាសព្រះបន្ទូល គឺប្រកាសអំពីគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត ដ្បិតខ្ញុំជាប់ឃុំឃាំងព្រោះតែគម្រោងការនេះឯង។ ៤សូមទូលអង្វរព្រះអង្គ ឲ្យខ្ញុំអាចបកស្រាយយ៉ាងច្បាស់លាស់ តាមដែលខ្ញុំត្រូវនិយាយ។

៥ចូរប្រព្រឹត្តចំពោះអស់អ្នក ដែលមិនមែនជាគ្រីស្តបរិស័ទដោយប្រើប្រាជ្ញា និងចេះប្រើប្រាស់ពេលវេលាផង។ ៦សូមបងប្អូននិយាយពាក្យសំដីទន់ភ្លន់ជានិច្ច មានខ្លឹមសារ[ឱ] ដើម្បីឲ្យបងប្អូនអាចឆ្លើយទៅម្នាក់ៗដោយសមរម្យ។

៧ទីឃីគូ ជាបងប្អូនដ៏ជាទីស្រឡាញ់របស់យើង ជាអ្នកបម្រើដ៏ស្មោះត្រង់ និងជាសហការីរបស់ខ្ញុំក្នុងកិច្ចការរបស់ព្រះអម្ចាស់ នឹងជម្រាបបងប្អូនឲ្យបានជ្រាបសព្វគ្រប់ អំពីសុខទុក្ខរបស់ខ្ញុំ។ ៨ខ្ញុំចាត់គាត់ ឲ្យមករកបងប្អូន ក្នុងគោលបំណងនេះឯង គឺឲ្យបងប្អូនបានដឹងដំណឹងពីយើង និងឲ្យគាត់លើកទឹកចិត្តបងប្អូនទៀតផង។ ៩ខ្ញុំចាត់គាត់ឲ្យមកជាមួយអូណេស៊ីមជាបងប្អូនដ៏ស្មោះត្រង់ និងដ៏ជាទីស្រឡាញ់ ជាអ្នកដែលនៅស្រុកជាមួយបងប្អូន។ អ្នកទាំងពីរនឹងជម្រាបបងប្អូន ឲ្យជ្រាបអំពីសភាពការណ៍នៅទីនេះ។

១០បងអរីស្តាក ដែលជាប់ឃុំឃាំងជាមួយខ្ញុំ សូមជម្រាបសួរមកបងប្អូន ហើយបងម៉ាកូដែលត្រូវជាសាច់ញាតិនឹងបងបារណាបា ក៏សូមជម្រាបសួរមកបងប្អូនដែរ (បងប្អូនបានទទួលពាក្យផ្ដាំផ្ញើ ស្ដីអំពីគាត់ស្រាប់ហើយ ប្រសិនបើគាត់មក សូមបងប្អូនទទួលដោយរាក់ទាក់ផង)។ ១១រីឯបងយេស៊ូហៅយូស្ទូ ក៏សូមជម្រាបសួរមកបងប្អូនផងដែរ។ ក្នុងចំណោមជនជាតិយូដា មានតែបងប្អូនបីនាក់នេះប៉ុណ្ណោះដែលធ្វើការសម្រាប់ព្រះរាជ្យ*ព្រះជាម្ចាស់ ជាមួយខ្ញុំហើយក៏បានលើកទឹកចិត្តខ្ញុំទៀតផង។ ១២បងអេប៉ាប្រាដែលនៅស្រុកជាមួយបងប្អូន ក៏សូមជម្រាប

សួរមកបងប្អូនដែរ។ គាត់ជាអ្នកបម្រើព្រះគ្រីស្ត
យេស៊ូ ហើយគាត់តែងតែតយុទ្ធសម្រាប់បងប្អូន
ដោយអធិស្ឋាន*ឥតឈប់ឈរដើម្បីឲ្យបងប្អូន
មានជំហររឹងប៉ឹង បានគ្រប់លក្ខណៈ និងសុខ
ចិត្តធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់គ្រប់
ជំពូកទាំងអស់។ ១៣ខ្ញុំហ៊ានធ្វើជាសាក្សីថា គាត់
បានខំប្រឹងខ្នះខ្នែងយ៉ាងខ្លាំង សម្រាប់បងប្អូន
សម្រាប់អស់អ្នកនៅស្រុកឡៅឌីសេ និង
អស់អ្នកនៅស្រុកយេរ៉ាប៉ូលីស៍។ ១៤គ្រូពេទ្យលូ
កាដ៏ជាទីស្រឡាញ់របស់យើង និងបងដេម៉ាស
ក៏សូមជម្រាបសួរមកបងប្អូនដែរ។

១៥សូមជម្រាបសួរបងប្អូន នៅស្រុកឡៅឌី
សេ និងជម្រាបសួរនាងនឹមផា ព្រមទាំងព្រះ
សហគមន៍ ដែលតែងប្រជុំគ្នានៅក្នុងផ្ទះគាត់
នោះផង។

១៦ពេលណាបងប្អូនអានសំបុត្រនេះរួច
ហើយ សូមលៃលកយ៉ាងណា ឲ្យព្រះសហគម
ន៍នៅស្រុកឡៅឌីសេអានផង ហើយបងប្អូនក៏
ត្រូវអានសំបុត្រ មកពីស្រុកឡៅឌីសេដែរ។
១៧សូមជម្រាបបងអឃីប៉ុសថា ត្រូវយកចិត្តទុក
ដាក់ចំពោះមុខងារ ដែលលោកបានទទួលពី
ព្រះអម្ចាស់ គឺត្រូវបំពេញកិច្ចការនេះឲ្យបាន
ល្អ។

១៨ពាក្យជម្រាបសួរនេះ ខ្ញុំប៉ូលសរសេរ
ដោយដៃខ្ញុំផ្ទាល់។ សូមបងប្អូនកុំភ្លេចថា ខ្ញុំជាប់
ឃុំឃាំង។ សូមព្រះជាម្ចាស់ប្រោសប្រណីបង
ប្អូន!

ក.ឃ្លាដើម«ព្រះគ្រីស្ដជារូបភាពរបស់ព្រះជាម្ចាស់»គឺបានសេចក្ដីថា ព្រះយេស៊ូធ្វើឲ្យយើងស្គាល់ព្រះជាម្ចាស់ដែលមនុស្សយើងមើលពុំឃើញ។•ខ.ពាក្យដើម«បល្ល័ង្ក»សំដៅទៅលើពពួកទេវតាដែលគ្រប់គ្រងពិភពលោកតាមជំនឿរបស់អ្នកក្រុងកូឡូស។•គ.ពាក្យដើម «ព្រះអង្គជារៀមច្បងនៃមនុស្សស្លាប់ទាំងអស់»។

ឃ.ពាក្យដើម:«កំណាប់តម្រិះនិងប្រាជ្ញា»។•ង.ពាក្យដើម«វិញ្ញាណ»។•ច. សូមអានសេចក្ដីពន្យល់«ន»នៅកាឡាទី៤.៣។

ឆ. យើងបកស្រាយថា«ពីដើមນបងប្អូនជាជនជាតិដទៃដែលមិនមែនជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់»។•ជ. ព្រោះគម្ពីរវិន័យនាំឲ្យយើងដឹងថាខ្លួនយើងមានបាប។•ឈ. យើងអាចបកប្រែថា«ក្នុងក្បួនជ័យជំនះរបស់ឈើឆ្កាង» ក៏បាន។

ញ.យើងប្រើពាក្យ«ព្នង»នេះដើម្បីបកប្រែពាក្យ«ជនជាតិស៊ីថ»(�ចយតហេ)។ជនជាតិស៊ីថជាកុលសម្ព័ន្ធមួយពួកដែលរស់នៅខាងជើងសមុទ្រខ្មៅ(ំរេណឹ ិរេ)ជាជនជាតិមួយដែលគេចាត់ទុកថាគ្មានអារ្យធម៌អ្វីទាំងអស់។•ដ. ឃ្លាដើម«ចំណងនៃសេចក្ដីគ្រប់លក្ខណៈ»។យើងអាចបកប្រែម៉្យាងទៀតថា:សេចក្ដីស្រឡាញ់នេះធ្វើឲ្យគុណសម្បត្តិ(ចិត្តមេត្តាចិត្តសប្បុរសចេះបន្ទាបខ្លួនນ-ខ១២-១៣) បានគ្រប់លក្ខណៈ។•ឋ. យើងអាចបកប្រែម៉្យាងទៀតថា«សណ្ឋិតនៅក្នុងចិត្ត»ក៏បាន។

ឌ. ពាក្យដើម «បង់អំបិល»។